

# ជីវិតម្ដាយ

MY MOTHER KEO NANN

## កែវ ណាន

ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩២៨ ~ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣



កែវ ណាន | KEO NANN

ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩២៨ ~ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣

# ជីវិតម្ដាយ

## MY MOTHER

នៅក្នុងជីវិតយើងម្នាក់ៗ តែងតែជួបប្រទះនូវហេតុការណ៍មួយចំនួន ដែលធ្វើឲ្យយើងនឹកគិតដល់គំនិតមួយ ក៏ដូចជាសំណួរមួយចំនួន ដែលហាក់បីដូចជាមានអាទិភាពខ្លាំងណាស់នៅពេញមួយជីវិតរបស់យើង។ ដូចជាហេតុការណ៍នៃការចូលមន្ទីរពេទ្យដំណាក់កាលចុងក្រោយរបស់ម្តាយខ្ញុំនាពេលថ្មីៗនេះ គឺជាកាលៈទេសៈមួយដែរ ហើយហេតុការណ៍នេះមិនត្រឹមតែជំរុញឲ្យខ្ញុំនឹកគិតដល់ជីវិតរបស់ម្តាយខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យខ្ញុំបាននឹកគិតទៅដល់ការលះបង់របស់គាត់ចំពោះក្រុមគ្រួសារ កូនចៅ ចៅទួត ក៏ដូចជាការលះបង់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់សម្រាប់ប្រជាជាតិកម្ពុជាទាំងមូល។

ម្តាយរបស់ខ្ញុំឈ្មោះ កែវ ណាន កើតនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩២៨ ត្រូវនឹងឆ្នាំម្សាញ់ នៅភូមិខ្មែរលើ ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ម្តាយរបស់ខ្ញុំ មានបងប្អូនប្រុសស្រីទាំងអស់៥នាក់ គឺ កែវ អឿន, កែវ នី (ស្រី), កែវ អៃ, កែវ ឈឿន និងរូបគាត់។ ឪពុករបស់គាត់ឈ្មោះ កែវ អឿ និងម្តាយរបស់គាត់ឈ្មោះ សាគូ ណម។ ម្តាយរបស់ខ្ញុំរៀបការជាមួយឪពុករបស់ខ្ញុំ ឈ្មោះ កែវ ទិន ដែលមានកំណើតនៅឆ្នាំ១៩២៣ ត្រូវនឹងឆ្នាំកុរ។ ឪពុករបស់ខ្ញុំ និងបងប្អូនទាំងអស់របស់ម្តាយខ្ញុំបានទទួលអនិច្ចកម្មអស់ហើយ។ ដូចទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀតដែរ គាត់មានកូនច្រើននាក់ ប៉ុន្តែកូនមួយចំនួនបានបាត់បង់ជីវិតអស់ទៅហើយ។ នៅលើលោកនេះប្រហែលជាគ្មានការឈឺចាប់ណា ស្មើនឹងការឈឺចាប់ ដែលកូនរបស់ខ្លួនត្រូវលាចាកលោកមុនឪពុកម្តាយនោះទេ ហើយរបបខ្មែរក្រហម គឺជារបបដែលបន្សល់ទុកនូវការឈឺចាប់ដ៏យូរអង្វែងមួយ ដែលធ្វើឲ្យកូនៗ ឪពុកម្តាយ និងគ្រួសាររបស់ពួកគាត់ជាច្រើនស្លាប់ទាំងគ្មានកំហុស។



Certain events in life force contemplation about topics and questions that deserve far greater priority during the entirety of our lives. My mother's recent hospitalization in the last stages of her life is one of these circumstances, and it has compelled me to reflect on not only my mother's life and her dedication to her family but also all survivors' sacrifice for the Cambodian Nation.

My mother's name is Keo Nann, and she was born on 4 March 1928, the year of the snake, in Khmer-Leu village, Ban-Kamm commune, Prey Kabas district, Takeo province. My mother had four siblings: Keo Oeun, Keo Ny (female), Keo Ay, and Keo Chhoeun. Her father's name is Keo Oeur, and her mother's name is Sakou Narm. My mother was married to my father, Keo Tin, whose birth year was in 1923, the year of the pig. Like many survivors of the Khmer Rouge, she gave birth to many children who never survived.

There is probably no greater curse than for parents to outlive their children and the Khmer Rouge period marked one long curse in the innocent deaths of so many children, their parents, and their family.

ម្ដាយរបស់ខ្ញុំ បានជួបរឿងដ៏គួរឲ្យរន្ធត់ច្រើនជាខ្លាំង ដោយគាត់ត្រូវប្រឈមមុខមើលកូនចំនួន៦នាក់ ក្នុងចំណោមកូន១០នាក់ ទទួលមរណភាព។ កូនខ្លះ ស្លាប់នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដ៏ឃោរឃៅ។ ខ្ញុំគឺជាកូនពៅដែលជាកូនទី ១០ ក្នុងគ្រួសារ ហើយម្ដាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា នៅពេលខ្ញុំកើតមក គាត់បានដាក់ឈ្មោះឲ្យខ្ញុំ ផ្សេងមួយទៀតទេ ប៉ុន្តែដោយសារតែការភ័យខ្លាច និងជំនឿផ្សេងៗផងនោះ គាត់ក៏បានដាក់ឈ្មោះដូចសព្វថ្ងៃនេះមកឲ្យខ្ញុំ (គាត់ហៅខ្ញុំថា៖ អាយុ ដែលឈ្មោះពេញនោះគឺ ទីឃាយុកោ)។ ឈ្មោះរបស់ខ្ញុំដែលគាត់ដាក់ឲ្យនៅពេលដែលខ្ញុំកើត គឺសំដៅលើថ្ងៃដែលខ្ញុំកើត គឺថ្ងៃចន្ទ (គាត់ដាក់ឈ្មោះថា ចន្ទ សុខ) ហើយគាត់ជឿថា ឈ្មោះនេះអាចជួយឲ្យខ្ញុំមានសំណាងល្អ អាចរស់រានមានជីវិតនៅក្នុងស្ថានភាពលំបាកដែលយើងរស់នៅក្នុងពេលនោះ។

កាលពីសម័យខ្មែរក្រហម ខ្ញុំនៅជាកូនក្មេងនៅឡើយ ហើយខ្ញុំមិនសូវដឹងច្រើនអំពីរបៀបរស់នៅនោះទេ។ ប៉ុន្តែខ្ញុំបានរៀនចេះអំពីរបៀបរស់បានយ៉ាងឆាប់រហ័ស ដោយសារតែខ្ញុំមិនអាចទ្រាំនឹងសេចក្ដីស្រេកឃ្លាន ដែលជាទារុណកម្មមួយដ៏ធ្ងន់ធ្ងរមកលើរូបខ្ញុំ។ ប៉ុន្តែ ដូចទៅនឹងបងប្អូនប្រុសស្រីបង្កើត របស់ខ្ញុំទាំងអស់ដែរ យើងតែងតែពឹងផ្អែកលើម្ដាយរបស់យើង ដើម្បីធ្វើជាអ្នកណែនាំ ពុះពារ និងជាអ្នកការពារ ថែទាំយើង ដ៏រឹងមាំមួយ។ នៅពេលរំឭកអំពីអតីតកាលបែបនេះ គឺធ្វើឲ្យខ្ញុំមានចិត្តមិនស្ងប់ នៅពេលនឹងគិតដល់តួនាទីម្ដាយរបស់ខ្ញុំនៅក្នុងគ្រួសារ នៅក្នុងសម័យកាលដ៏លំបាកលំបិនបំផុតនោះ និងការទទួលស្គាល់ តួនាទីរបស់គាត់ដែលកាន់តែតិចទៅៗនៅបណ្ដាឆ្នាំក្រោយៗមកទៀត នៅក្នុងក្រុមគ្រួសាររបស់យើង។ ក្ដីរន្ធត់ដ៏ខ្លាំងប្រៀបបានទៅនឹងរបបខ្មែរក្រហមដែរនោះ ខ្ញុំគិតថាស្មារតីរបស់ម្ដាយខ្ញុំ និងការផ្ដល់តម្លៃលើខ្លួនឯង គឺពិតជាអស្ចារ្យណាស់ក្នុងពេលនោះ ដោយសារតែយើងទាំងអស់គ្នាពឹងផ្អែកទៅលើគាត់ ដើម្បីអាចរស់បាន ហើយគាត់និងយើងទាំងអស់គ្នា ពិតជាទទួលស្គាល់ថានេះគឺជាការពិត។



My mother lived this nightmare, watching six children pass away out of the 10 children she had—some died before, during and after the brutal years of war and the Khmer Rouge genocide.

I was the youngest child, number 10, and she told me that she had another name for me when I was born, but out of fear and superstition, she gave me my present name. She called me A-Youk, which means 'life' and is the short form of Tikheayoukor in Pali. My birth name refers to the day I was born, which was on Monday. She named me Chan [Monday] Sok, which means 'safe or peace'. She believed having this name could bring me good fortune in surviving the difficult times we lived in.

During the Khmer Rouge period, I was just a small boy, and I did not initially have many survival skills. I quickly learned how to survive because hunger can be a powerful tutor. But, like all my siblings, we looked to our mother as a rock of guidance, perseverance, and care.

Looking back, it makes me sad to reflect upon my mother's role in our family and our family's diminishing acknowledgment of this role in later years. As horrific as the Khmer Rouge period was, I think my mother's spirit and sense of self-value were greatest during this period because we all depended upon her for our survival, and she and we recognized this reality.

មានការលើកឡើងផ្ទុយគ្នា យ៉ាងហោចណាស់ចំពោះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួន ដែលថាស្មារតីនៃការសម្រេចគោលបំណង និងតម្លៃគុណបំណាច់មួយចំនួន កើតឡើងដោយសារការឆ្លងកាត់សម័យខ្មែរក្រហម ហើយនៅពេលដែលជីវិតយើងមានភាពល្អប្រសើរសង្គម មានការវិវឌ្ឍទៅមុខ ស្មារតីនៃការសម្រេចតម្លៃគុណបំណាច់នេះហាក់បីដូចជាមានការធ្លាក់ចុះ រហូតក្លាយទៅជាការចងចាំមួយដែលត្រូវបានគេបំភ្លេចចោលសម្រាប់សង្គមកម្ពុជា បើទោះបីជាមិនមានការបំភ្លេចចោលទាំងស្រុងយ៉ាងណាក្តី។

នៅក្រោយរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ខ្ញុំ និងខ្ញុំ នៅតែពឹងផ្អែកទៅលើជំហររឹងមាំរបស់ម្តាយយើង ប៉ុន្តែនៅពេលដែលពេលវេលាចេះតែរំកិលទៅមុខហើយជីវិតក៏ចាប់ផ្តើមត្រលប់ទៅរកភាពនឹងនរ និងធម្មតាវិញម្តងបន្តិចៗ យើងក៏បានចាប់ផ្តើមលែងសូវពឹងផ្អែកទៅលើម្តាយរបស់យើងតទៅទៀតដែរ។ ហើយនៅពេលដែលម្តាយរបស់យើង មានវ័យកាន់ តែចាស់ទៅៗ យើងមិនបានចងចាំអំពីស្មារតី ភាពរឹងមាំ ការដឹកនាំ ភាពនឹងនរ និងការថែទាំដូចដែលគាត់មានកាលពីនៅក្មេងទៀតឡើយ។

កូនៗរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ជំនាន់កូនរបស់ពួកគេ និងអ្នកជំនាន់ក្រោយៗ មិនត្រូវភ្លេចទេថា ឪពុកម្តាយរបស់យើងដែលបានរស់ក្នុងរបបខ្មែរក្រហមនោះ មិនត្រឹមតែដើរតួនាទីជាឪពុកម្តាយ ជីដូនជីតា តាទួតយាយទួត របស់អ្នកជំនាន់ក្រោយនេះនោះទេ លើសពីនេះគាត់ទាំងអស់ក៏ជាវីរៈជន ដែលមានគុណូបការៈចំពោះប្រទេសជាតិទៀតផង។



The irony is, at least for some survivors, there was a sense of purpose and value that came out of the long night known as the Khmer Rouge period, and as life improved and society moved on, this sense of value receded—becoming a diminished, if not entirely forgotten, memory to Cambodian society.

After the Khmer Rouge period, my family and I still looked to our mother for strength, but as time passed and life slowly returned to some semblance of stability and normalcy, we depended upon our mother less. And as our mother aged, we did not recognize her as much for her spirit, strength, and the rock of guidance, stability and care that had come to define her person in our younger years.

The children of survivors, their children, and future generations must not forget that the generation of parents that survived the Khmer Rouge are not only parents (and grand-parents) to future generations, they are also heroes that this nation owes a great service to. It is only today, as my mother's health steadily declines, that I realized how much I owe her, and how much all Cambodian society owes this generation of heroes that kept their families alive during such a horrendous period.

រហូតទាល់តែដល់ថ្ងៃនេះ ដែលស្ថានភាពសុខភាពម្ដាយរបស់ខ្ញុំ ចុះខ្សោយជាបន្តបន្ទាប់ ទើបខ្ញុំភ្ញាក់ខ្លួនថា ខ្ញុំនៅជំពាក់គុណបំណាច់គាត់ដ៏មហាធំធេង ហើយសង្គមខ្មែរនៅជំពាក់គុណូបការៈចំពោះ វីរៈជនជំនាន់នោះយ៉ាងច្រើនលើសលុបក្នុងការជួយថែរក្សាជីវិតគ្រួសាររបស់គាត់ទាំងអស់ ដែលរស់រាននៅក្នុងសម័យកាលដ៏យង់ឃ្នងមួយនេះ។

ខ្ញុំសូមសម្ដែងនូវការដឹងគុណជាអនេកចំពោះក្រុមវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកដែលបានជួយព្យាបាលនិងថែទាំម្ដាយរបស់ខ្ញុំ ជាពិសេសគឺ លោកវេជ្ជបណ្ឌិតវ័យ ក្មេង ឆ ប៊ុនប៉ូល ឯកទេសផ្នែកថែទាំសួត និងផ្លូវដង្ហើម។ ហើយខ្ញុំក៏សូមដឹងគុណដល់វេជ្ជបណ្ឌិត កាំង គីមសាន និង លោកប្រធានវេជ្ជបណ្ឌិត បូរី សុថាណារិទ្ធ និងវេជ្ជបណ្ឌិត ភោគ សុវណ្ណ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីសំណាក់ប្រទេសបារាំងក្នុងប្រព័ន្ធសុខាភិបាលសាធារណៈរបស់ប្រទេសកម្ពុជា ដែលការរួមចំណែកនេះពិតជាបានផ្ដល់ជាជំនួយជាច្រើនដល់ប្រជាជនកម្ពុជាដែលមានតម្រូវការផ្នែកថែទាំវេជ្ជសាស្ត្រទំនើប ព្រមទាំងវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកវ័យក្មេងដែលបម្រើការងារនៅទីនោះ។ ការរួមចំណែកនេះ បានផ្ដល់ឱកាសដល់យុវជនកម្ពុជាវ័យក្មេងក្នុងការសិក្សា អនុវត្ត និងសម្រួចជំនាញ និងឯកទេសរបស់ខ្លួននៅមណ្ឌលវេជ្ជសាស្ត្រដែលមានវិជ្ជាជីវៈខ្ពស់បែបនេះ។ គិលានុបដ្ឋាយិកាដែលក្លាយជាក្រុមគ្រួសារមួយរបស់ខ្ញុំគឺ លោកគ្រូពេទ្យ បញ្ញា លោកគ្រូពេទ្យ រ៉ាន់ លោកគ្រូពេទ្យ បូ និងលោកគ្រូពេទ្យ សា។ សរុបមក ម្ដាយរបស់ខ្ញុំនឹងមិនអាចមានជីវិតរស់រានបានឡើយ ប្រសិនបើគ្មានការថែទាំពីសំណាក់វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកទាំងនោះ។



I am grateful to the team of doctors, nurses, and staff that have supported my mother's medical treatment and care, in particular, a young Cambodian doctor named Dr. Chor Bun Paul, who is an expert in lung and respiratory care. I am also grateful to Dr. Kaing Kim Sann, the Chief of Doctors, Dr. Borey Sothanarith, and Dr. Phork Sovann, Head of the ICU.

I also want to thank the French contributions to Cambodia's public health system, which have been a tremendous help not only to the Cambodian people who are in desperate need of modern medical care, but also the young Cambodian doctors, nurses, and staff who work in these institutions.

These contributions have given these young Cambodians an opportunity to learn, practice and hone their skills and expertise in professional medical settings. I also want to thank four nurses, including Panha, Rann, Bo and Sa. There is no doubt, my mother would not be alive today without the tremendous care she has received from all doctors, nurses and staff.

Without question, the Cambodian Nation would not be the strong, resilient nation that exists today if it did not possess the strength, sacrifice, and heroism of the generation that survived the Khmer Rouge. We owe them our undying gratitude, respect, and honor.

As I write this, my mother is still alive, but I am not sure she will be alive by the time this post is published. Her life lies in God's hands, and I am left praying for a miracle that He will care for her.



ជារួម ប្រទេសកម្ពុជា នឹងមិនអាចក្លាយជាប្រទេសដ៏រឹងមាំ និងមានភាពធន់រហូតមកដល់សព្វថ្ងៃនេះបានដែរ ប្រសិនបើគ្មានភាពរឹងមាំ ការលះបង់ និងវីរភាពរបស់មនុស្សចាស់ជំនាន់មុនដែលបានឆ្លងកាត់របបខ្មែរក្រហម។ យើងពិតជាមានការដឹងគុណ សេចក្ដីគោរព និងសូមផ្ដល់កិត្តិយសដ៏ខ្ពង់ខ្ពស់ចំពោះគាត់គ្រប់ៗគ្នា។ នៅពេលដែលខ្ញុំសរសេរអត្ថបទនេះ ម្ដាយរបស់ខ្ញុំគឺនៅមានជីវិតនៅឡើយទេ ប៉ុន្តែខ្ញុំពិតជាមិនដឹងទេថា តើគាត់អាចនឹងនៅបន្តមានជីវិតរហូតដល់ពេលដែលអត្ថបទនេះត្រូវបានចុះផ្សាយជាសាធារណៈដែរឬទេ។ ជីវិតរបស់គាត់ គឺស្ថិតនៅក្នុងដៃទេវតាទៅហើយ ហើយខ្ញុំមិនមានអ្វីក្រៅពីការបួងសួងសូមឲ្យទេវតាថែរក្សាគាត់ជាប់ជានិច្ចតទៅ។

## អវសានបទ

ម្ដាយរបស់ខ្ញុំចាប់ផ្ដើមមានជរាពាធ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ហើយទទួលមរណភាព នៅ ថ្ងៃសៅរ៍ ៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹង ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២និង៣៣នាទីភ្លឺ។

## POST-SCRIPT

On 20 June 2023, my mother entered the final hours of her remarkable life. At 2:33 a.m., on Saturday, the fourth day of the eighth month, in the year of the rabbit, and year 2567 in the Buddhist Era and 5 August 2023 of the Gregorian Calendar, Keo Nann, matriarch and honored mother of 10 children and a heroic survivor of the Khmer Rouge era, passed onto the next life.





# សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្ដម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា

ជូន លោក យុ ឆាំង
នាយក នៃមជ្ឈមណ្ឌលឯកសារកម្ពុជា
និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត

លោកនាយក

ខ្ញុំ បានទទួលដំណឹងដ៏ក្រៀមក្រំអំពីការទទួលមរណភាព **ព្រឹទ្ធមហាឧបាសិកា កែវ ណាន** មាតាបង្កើតជាទីគោរពស្រឡាញ់របស់លោកនាយកនៅ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ ដោយរោគាពាធក្នុងជន្មាយុ ៩៥ឆ្នាំ។

ខ្ញុំ សូមចូលរួមរំលែកមរណទុក្ខ និងសូមសម្ដែងនូវការសោកស្ដាយជាមួយលោកនាយក និងក្រុមគ្រួសារ ព្រមទាំងញាតិមិត្តទាំងអស់នៃសព។ មរណភាពនៃព្រឹទ្ធមហាឧបាសិកា កែវ ណាន ជាការបាត់បង់មាតា មាតាក្មេក និងជីដូន ជីដូនទួត

ដែលប្រកបដោយព្រហ្មវិហារធម៌ដ៏ល្អប្រពៃមួយរូប ដែលបានខិតខំអប់រំដល់បុត្រា បុត្រី និងជាពុទ្ធសាសនិកជនដ៏ខ្ជាប់ខ្ជួនជាទីគោរពស្រឡាញ់នៃមហាជន។

សូមវិញ្ញាណក្ខន្ធ ព្រឹទ្ធមហាឧបាសិកា កែវ ណាន អញ្ជើញទៅកាន់សុគតិភព កុំបីអាក់ខានឡើយ។

សូម លោកនាយក ទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ។

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣





សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

ជូន លោក យុ ឆាង
នាយក នៃមជ្ឈមណ្ឌលឯកសារកម្ពុជា
និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត

លោកនាយក

ខ្ញុំ បានទទួលដំណឹងដ៏ក្រៀមក្រំអំពីការទទួលមរណភាព **ព្រឹទ្ធមហាឧបាសិកា កែវ ណាន** មាតាបង្កើតជាទីគោរពស្រឡាញ់របស់លោកនាយកនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ ដោយរោគាពាធក្នុងជន្មាយុ ៩៥ឆ្នាំ។

ខ្ញុំ សូមចូលរួមរំលែកមរណទុក្ខ និងសូមសម្តែងនូវការសោកស្តាយជាមួយលោកនាយក និងក្រុមគ្រួសារ ព្រមទាំងញាតិមិត្តទាំងអស់នៃសព។ មរណភាពនៃ **ព្រឹទ្ធមហាឧបាសិកា កែវ ណាន** ជាការបាត់បង់មាតា មាតាក្មេក និងជីដូន ជីដូនទួត ដែលប្រកបទៅដោយព្រហ្មវិហារធម៌ដ៏ល្អប្រពៃមួយរូប ដែលបានខិតខំអប់រំដល់បុត្រា បុត្រី និងជាពុទ្ធសាសនិកជនដ៏ខ្ជាប់ខ្ជួនជាទីគោរពស្រឡាញ់នៃមហាជន។

សូមវិញ្ញាណក្ខន្ធ **ព្រឹទ្ធមហាឧបាសិកា កែវ ណាន** អញ្ជើញទៅកាន់សុគតិភពកុំបីអាក់ខានឡើយ។

សូម លោកនាយក ទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ។

នរោត្តម មុនិនាថ សីហនុ

ភ្នំពេញថ្ងៃទី ៦ ខែសីហា ឆ្នាំ២០២៣

## ព្រះរាជសទនីយ៍ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
## នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា

### សូមជូនលោក យុ ឆាំង

ខ្ញុំ ហ្លួងម៉ែ សូមសម្តែងការសោកស្តាយបំផុត ចំពោះមរណភាពរបស់លោកយាយម្តាយលោក ដែលលោកជាអ្នកស្មោះហាជាតិ លោកអ្នកធ្វើបុណ្យ។ ខ្ញុំ សោកស្តាយណាស់មិនបានជួបលោកយាយម្តងទៀត មុនគាត់អញ្ជើញទៅ។ តែសូមលោក យុ ឆាំង លោកកុំព្រួយពេក លោកអញ្ជើញទៅលើមេឃហើយ។ លោកយាយ លោកសុខសប្បាយទេ សូមឲ្យវិញ្ញាណក្ខន្ធលោកយាយ បានសុខសប្បាយនៅឋានសួគ៌ ហើយជួយគ្រប់គ្រងពីលើមេឃមក គ្រប់គ្រងលោក ហើយនិងបងប្អូនទាំងអស់ គ្រួសារទាំងអស់។

សូមសោកស្តាយម្តងទៀត។

All my condolences to you and your family.

**ហ្លួងម៉ែ**

ភ្នំពេញថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣







# កែវ ឈាន

ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩២៨ ~ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣